# សិក្ខាសាលាជាតិ
## ស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥
## របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
## សាលប្រជុំ ក្រសួងមហាផ្ទៃ ថ្ងៃទី០៤-០៥ ខែកុម្ភៈ ឆ្នាំ២០១៥

---

### របាយការណ៍សង្ខេបស្តីពីលទ្ធផលនៃសិក្ខាសាលាជាតិ

ដោយ ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

- សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សូមគោរពឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកា គ.ជ.អ.ប.
- សូមគោរពឯកឧត្តម លោកជំទាវ លោកស្រី អស់លោក តំណាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សូមគោរពអស់លោក លោកស្រីជាតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា
- អង្គសិក្ខាសាលាជាតិទាំងមូលជាទីគោរព!

តាងនាមឲ្យសមាជិក សមាជិកានៃអង្គសិក្ខាសាលា ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពអនុញ្ញាតធ្វើសេចក្តីរាយការណ៍សង្ខេបជូន**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងគណៈអធិបតី អំពីលទ្ធផលនៃ**សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥ របស់ គ.ជ.អ.ប** ដែលបានប្រព្រឹត្តទៅចាប់ពីព្រឹកម្សិលមិញរហូតមកដល់ពេលនេះ ដូចតទៅ ៖

## អំពីអ្នកចូលរួម

យោងតាមការអញ្ជើញរបស់គ.ជ.អ.ប សិក្ខាសាលានេះមានការចូលរួមពីសមាជិក សមាជិកាប្រមាណ**៤៣០នាក់** ក្នុងនោះរួមមានស្ត្រី៩២នាក់ ដែលមានសមាសភាពមកពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានានៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធមួយចំនួននៅរាជធានីខេត្ត ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលមួយចំនួន។

ជារួម សិក្ខាសាលានេះ បានអញ្ជើញតួអង្គពាក់ព័ន្ធសំខាន់ៗនៅថ្នាក់ជាតិ និងភាគច្រើនមកពីរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានចំនួនប្រមាណ**៦៥%**នៃអ្នកចូលរួមសរុប ដែលតំណាងឱ្យសំឡេងពីរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងលើកកម្ពស់ការចូលរួមអនុវត្ត និងការទទួលខុសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលជាអ្នកអនុវត្តផ្ទាល់ ចាប់តាំងពីដំណាក់កាលនៃការរៀបចំផែនការរហូតដល់ដំណាក់កាលនៃការអនុវត្ត។

## អំពីកិច្ចដំណើរការសិក្ខាសាលា

អង្គសិក្ខាសាលាទាំងមូលបានចាប់ផ្តើមកិច្ចដំណើរការដោយមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដែលបាន

ស្តាប់នូវមតិណែនាំក្នុងសុន្ទរកថាបើករបស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់ អនុប្រធាន គ.ជ.អ.ប** ដែលបានគូសបញ្ជាក់អំពីគោលបំណងនៃសិក្ខាសាលា និងផ្តល់គោលការណ៍ណែនាំតម្រង់ទិសនានាជូនអង្គសិក្ខាសាលាក្នុងការពិភាក្សាពិគ្រោះយោបល់ និងផ្តល់ធាតុចូលជាគន្លឹះនានាក្នុងការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥ របស់ គ.ជ.អ.ប។ **ឯកឧត្តម** បានផ្តល់នូវអនុសាសន៍សំខាន់ៗជាច្រើនពាក់ព័ន្ធ ជាពិសេសពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុ។ ជាមួយគ្នានេះដែរ ឯកឧត្តម ក៏បានឆ្លៀតឱកាសគូសបញ្ជាក់បន្ថែមអំពីការដាក់ចេញនូវគោលការណ៍ថ្មីៗរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធទៅនឹងការលើកកម្ពស់ជីវភាពរបស់កម្មករនិយោជិតដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវយកចិត្តទុកដាក់ ក្នុងនោះរួមមានវិធាននានាពាក់ព័ន្ធនឹងការកាត់បន្ថយថ្លៃទឹក ថ្លៃភ្លើង និងថ្លៃឈ្នួលផ្ទះ ឬបន្ទប់ដែលកម្មករបានជួល និងបញ្ហាផ្តល់ប្រាក់កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

អង្គសិក្ខាសាលាបានស្តាប់នូវបទបង្ហាញអំពីវឌ្ឍនភាពនិង បញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ ឆ្នាំ២០១៤ បទបង្ហាញអំពីមូលនិធិប៉ាន់ស្មានសម្រាប់ការរៀបចំផែន ផ.ស.ថ ២០១៥ និងការវិភាជន៍មូលនិធិកញ្ចប់រួមឱ្យស្ថាប័នអនុវត្តថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ បទបង្ហាញស្តីពីការវិភាជន៍ថវិការដ្ឋសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ បទបង្ហាញស្តីពីសកម្មភាពចម្បងៗចំនួន២១នៃផអ៣ទី២ដែលត្រូវសម្រេចឱ្យបានក្នុងឆ្នាំ២០១៥ និងបានស្តាប់នូវមតិចូលរួមយោបល់របស់តំណាងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនឹងការរៀបចំនិងការអនុវត្ត ផ.ស.ថ ២០១៥។

បន្ទាប់ពីបានស្តាប់នូវបទបង្ហាញនានា អង្គសិក្ខាសាលាក៏បានបែងចែកជា៦ក្រុមពិភាក្សាដើម្បីពិគ្រោះពិភាក្សាទៅលើសេចក្តីព្រាងសកម្មភាពជាអាទិភាពចំនួន២១ក្នុងសមិទ្ធផលទាំង៥នៃផអ៣ទី២ដែលត្រូវសម្រេចឱ្យបានក្នុងឆ្នាំ២០១៥ តាមរយៈការកំណត់នូវបញ្ហាប្រឈម ដំណោះស្រាយ និងក្របខ័ណ្ឌពេលវេលា ក៏ដូចជាការលើកកម្ពស់សមធម៌និងបរិយាប័ន្នសង្គម ដើម្បីសម្រេចបាននូវសកម្មភាពជាអាទិភាពទាំងនោះ។

ផ្អែកលើការពិភាក្សាអំពីបញ្ហាប្រឈមនៃការអនុវត្ត ផ.ស.ថ ឆ្នាំ២០១៤ និងសកម្មភាពជាអាទិភាពទាំង២១ ដែលបានគ្រោងឡើង អង្គសិក្ខាសាលាបានទទួលនូវការចូលរួមយោបល់ពីក្រុមពិភាក្សាទាំង ៦ ដែលខ្ញុំសូមអនុញ្ញាតិធ្វើរបាយការណ៍ជាសង្ខេប ដូចតទៅ៖

ជារួមអង្គសិក្ខាសាលាទាំងមូល បានសម្តែងនូវការគាំទ្រ និងឯកភាពទាំងស្រុងទៅលើសកម្មភាពជាអាទិភាពទាំង២១ ដែលគ្រោងដើម្បីឈានទៅសម្រេចឱ្យបាននៅក្នុងឆ្នាំ២០១៥នេះ។

ជាមួយគ្នានោះ អង្គសិក្ខាសាលាក៏បានពិភាក្សា និងកំណត់ នូវបញ្ហាប្រឈមជាគន្លឹះមួយចំនួនដែលពាក់ព័ន្ធនឹងការសម្រេចឱ្យបានសកម្មភាពជាអាទិភាពទាំង២១ ដូចខាងក្រោម៖

**អំពីការគ្រប់គ្រងការងារកំណែទម្រង់**

ក្រុមពិភាក្សាបានសម្តែងនូវការព្រួយបារម្ភអំពីភាពមិនស៊ីសង្វាក់និងការពុំសូវមានកិច្ចសហការគ្នារវាងក្រសួង ស្ថាប័ននានា ក្នុងការរៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុទ្ធ និងសៀវភៅណែនាំនានា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អង្គសិក្ខាសាលា បានសំណូមពរឱ្យមានការសម្របសម្រួលកាន់តែជិតស្និទ្ធិ និងព្រមព្រៀងគ្នាជាមុនរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ទៅលើលិខិតបទដ្ឋាននានា

មុននឹងដាក់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្ត។ ជាមួយគ្នានោះដែរ រាល់កិច្ចប្រជុំសំខាន់ៗចាំបាច់ ត្រូវយកចិត្តទុកដាក់ទៅលើបញ្ហាបរិយាប័ន្ន និងសមធម៌សង្គមនៅក្នុងរបៀបវារៈរបស់កិច្ចប្រជុំនោះ។

**អំពីគណនេយ្យភាពបែបប្រជាធិបតេយ្យ**

ការងារគណនេយ្យភាពសង្គមជាការងារថ្មី អាស្រ័យហេតុនេះ ចាំបាច់ត្រូវជម្រុញនូវការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីធានាដល់ការចូលរួមពីប្រជាពលរដ្ឋ និងក្រុមនានាក្នុងសហគមន៍ក្នុងការចាប់ផ្តើមអនុវត្តការងារដ៏មានសារៈសំខាន់នេះ ជាពិសេសពាក់ព័ន្ធវិស័យសុខាភិបាល អប់រំ និងការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ជាមួយគ្នានេះដែរ សមត្ថភាពមន្ត្រីសម្របសម្រួលសហគមន៍ ក៏ទាមទារឱ្យមានការបណ្តុះបណ្តាលមានលក្ខណៈស៊ីជំរៅផងដែរ ដើម្បីធានាដល់ការអនុវត្តការងារគណនេយ្យភាពសង្គមទទួលបានជោគជ័យ។

**អំពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស**

ការរៀបចំលក្ខន្តិកៈសម្រាប់មន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពយឺតយ៉ាវ ។ អាស្រ័យហេតុនេះ អង្គសិក្ខាសាលាបានស្នើឱ្យក្រសួងពាក់ព័ន្ធជំរុញការងារនេះឱ្យសម្រេចបានតាមផែនការឆ្នាំ២០១៥ និងធ្វើការកំណត់អំពីការផ្តល់តំណែងឱ្យបានច្បាស់លាស់សម្រាប់ស្ត្រីនៅគ្រប់មុខតំណែងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ភាពមិនច្បាសលាស់អំពីសមត្ថភាពរបស់ទីប្រឹក្សានៅមណ្ឌលធនធានរាជធានី ក្នុងការអភិវឌ្ឍសមត្ថភាពលើគ្រប់ប្រធានបទសម្រាប់លើកម្ពស់សមត្ថភាពទាំងក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ជាក្តីកង្វល់ដ៏សំខាន់របស់អង្គសិក្ខាសាលាដែលស្នើសុំឱ្យមានការយកចិត្តទុកដាក់ដោះស្រាយបញ្ហានេះឱ្យបានច្បាស់លាស់។ ជាមួយគ្នានេះដែរ ការប្រមូលផ្តុំទីប្រឹក្សាក្រុង ស្រុកមកក្នុងមណ្ឌលធនធានមនុស្សរាជធានី ខេត្ត អាចនាំឱ្យប្រសិទ្ធភាពការងាររបស់ក្រុង ស្រុកមានការថយចុះ។ អាស្រ័យហេតុនេះ ស្នើឱ្យក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប យកចិត្តទុកដាក់ និងពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីធានាដល់កិច្ចដំណើរការរបស់មណ្ឌលធនធាន និងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

អង្គសិក្ខាសាលាក៏បានស្នើឱ្យបន្តយកចិត្តទុកដាក់ក្នុងការលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពអំពីភាពអង់អាចរបស់ស្ត្រី រួមទាំងសមធម៌និងបរិយាប័ន្ន ដល់ថ្នាក់ដឹកនាំនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាពង្រឹងការរៀបចំ ការអនុវត្ត និងការតាមដាន និងការវាយតម្លៃអំពីការអភិវឌ្ឍសមត្ថភាពនេះ ឱ្យបានច្បាស់លាស់ និងទៀងទាត់។

**អំពីការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

មុខងារមួយចំនួនដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ពុំមាននៅក្នុងផែនការថវិការបស់ក្រសួងជំនាញ ឧទាហរណ៍ដូចជាការងារមត្តេយ្យសហគមន៍ គឺមានតែមុខងារ ប៉ុន្តែពុំមានថវិកាសម្រាប់ការអនុវត្ត។ អាស្រ័យហេតុនេះ សូមស្នើឱ្យក្រសួងវិស័យអាទិភាពនានា ពិចារណាក្នុងការជម្រុញកិច្ចដំណើរការផ្ទេរមុខងារចាំបាច់មួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយរួមបញ្ចូលទាំងការផ្ទេរនូវធនធានហិរញ្ញវត្ថុ សម្រាប់គាំទ្រមុខងារដែលត្រូវផ្ទេរទាំងនោះផងដែរ។

**អំពីវិមជ្ឈការហិរញ្ញវត្ថុ**

រហូតដល់ពេលនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ ពុំទាន់មានប្រភពចំណូលផ្ទាល់ខ្លួននៅឡើយទេ។ អាស្រ័យហេតុនេះ សូមថ្នាក់ជាតិ ជំរុញការរៀបចំ និងអនុវត្តលិខិតបទដ្ឋាននានា ពាក់ព័ន្ធនឹងប្រភពចំណូលផ្ទាល់ឱ្យបានឆាប់។

ជារួម ខ្ញុំសូមគោរពរាយការណ៍ជូនគណៈអធិបតីមេត្តាជ្រាបថា ផែនការសកម្មភាពនិងថវិកាឆ្នាំ ២០១៥នឹងត្រូវអនុវត្តដោយក្រសួង ស្ថាប័នចំនួន២០ រដ្ឋបាលរាជធានី ខេត្តទាំង ២៥ និងក្រុង ស្រុក ខណ្ឌចំនួន ១៩៧ រួមទាំងអង្គការសង្គមស៊ីវិល និងវិស័យ ឯកជនមួយចំនួនទៀត។

ធនធានប៉ាន់ស្មានសរុប សម្រាប់គាំទ្រដល់ការសម្រេចបាននូវសកម្មភាពជាអាទិភាពទាំង២១ នៃផអ៣ក្នុងឆ្នាំ២០១៥ មានចំនួនប្រមាណ**៣២៥លាន**ដុល្លារ ដែលក្នុងនោះរួមមានធនធានរបស់រាជរដ្ឋាភិបាលមានចំនួនប្រមាណ**២៧៧លាន**ដុល្លារ ដែលត្រូវបែងចែកដល់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ និងធនធានចូលរួមចំណែករបស់ដៃគូអភិវឌ្ឍន៍មានចំនួនប្រមាណ**៤៧លាន**ដុល្លារ។

ជាទូទៅសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥របស់ គ.ជ.អ.ប ដែលបានរៀបចំឡើងរយៈពេលមួយថ្ងៃកន្លះនេះ បានប្រព្រឹត្តទៅប្រកបដោយភាពរលូនតាមកម្មវិធី ដោយមានការចូលរួមផ្តល់យោបល់យ៉ាងផុលផុស និងទទួលបានលទ្ធផលជាផ្លែផ្កាដូចគោលបំណងដែលបានគ្រោងទុក។ លេខាធិការដ្ឋាន គ.ជ.អ.ប បានកត់ត្រានូវរាល់អនុសាសន៍នានាដែលអង្គសិក្ខាសាលាបានលើកឡើង ដើម្បីរៀបចំកែសម្រួលនូវសេចក្តីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥ នេះ មុននឹងដាក់ជូន គ.ជ.អ.ប ពិនិត្យ និងសម្រេចក្នុងពេលឆាប់ៗខាងមុខនេះ។

អាស្រ័យដូចបានគោរពរាយការណ៍ជូនខាងលើ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងគណៈ អធិបតី មេត្តាជ្រាបជារបាយការណ៍។

**សូមអរគុណ**